ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ........................................................

# សុន្ទរកថា
## លោកជំទាវ ជា សិរី ឧបការីទេសាភិបាល និងជាអគ្គនាយកបច្ចេកទេស
## ថ្លែងក្នុងពិធីចុះអនុស្សរណៈយោគយល់ រវាងធនាគារជាតិនៃកម្ពុជា និងបេឡាជាតិសន្តិសុខសង្គម (ប.ស.ស.)ស្តីពី កម្មវិធីបណ្តុះបណ្តាលធនធានមនុស្សផ្នែកគ្រប់គ្រងការវិនិយោគ
## (តាមប្រព័ន្ធអនឡាញ)

ថ្ងៃព្រហស្បតិ៍ ៥រោច ខែទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ត្រូវនឹងថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២១ វេលាម៉ោង ១០:០០ នាទីព្រឹក

**ជាបឋម សូមគោរព!!!**

- **ឯកឧត្តម អ៊ុក សមវិទ្យា ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយកបេឡាជាតិសន្តិសុខសង្គម**
- **ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា**

ថ្ងៃនេះ នាងខ្ញុំមានកិត្តិយស និងសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែង ដែលបានចូលរួមតាមប្រព័ន្ធអនឡាញក្នុងពិធីចុះអនុស្សរណៈយោគយល់រវាងធនាគារជាតិនៃកម្ពុជា និងបេឡាជាតិសន្តិសុខសង្គមស្តីពី**កម្មវិធីបណ្តុះបណ្តាលធនធានមនុស្សផ្នែកគ្រប់គ្រងការវិនិយោគ។** ការរៀបចំពិធីចុះអនុស្សរណៈយោគយល់តាមរយៈប្រពន្ធ័អនឡាញនាថ្ងៃនេះ គឺដើម្បីបង្កើតក្របខណ្ឌកិច្ចសហប្រតិបត្តិការបច្ចេកទេសមួយដើម្បីជួយកសាងសមត្ថភាពធនធានមនុស្សសម្រាប់ការគ្រប់គ្រងការវិនិយោគមូលនិធិសន្តិសុខសង្គមរបស់ ប.ស.ស. តាមរយៈការចែករំលែកចំណេះដឹង និងបទពិសោធន៍របស់មន្ត្រីជំនាញផ្នែកគ្រប់គ្រងការវិនិយោគទុនបម្រុងអន្តរជាតិរបស់ធនាគារជាតិនៃកម្ពុជា។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា!**

ធនាគារជាតិនៃកម្ពុជាគ្រប់គ្រងទុនបម្រុងអន្តរជាតិរបស់ប្រទេសកម្ពុជាដោយអនុលោមតាមច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តិទៅរបស់ធនាគារជាតិនៃកម្ពុជា។ ដូច្នេះ ទុនបម្រុងអន្តរជាតិត្រូវបានគ្រប់គ្រងប្រកបដោយការទទួលខុសត្រូវ និងបច្ចេកទេសវិនិយោគខ្ពស់ស្របតាមស្តង់ដារអន្តរជាតិដោយរក្សាបានគោលដៅលំដាប់អាទិភាពៈ សុវត្ថិភាព សន្ទនីយភាព និងចំណូល។ ធនាគារជាតិនៃកម្ពុជាបានចាត់ចែងការគ្រប់គ្រងទុនបម្រុងអន្តរជាតិតាមរយៈការកសាងរចនាសម្ព័ន្ធគ្រប់គ្រងមួយដ៏រឹងមាំដែលដឹកនាំដោយក្រុមប្រឹក្សាភិបាលធនាគារជាតិនៃកម្ពុជា និងគណៈកម្មការវិនិយោគទុនបម្រុងអន្តរជាតិ។ ជាងនេះទៀត ធនាគារជាតិនៃកម្ពុជាបានផ្តោតការយកចិត្តទុកដាក់ជាចម្បងលើការអភិវឌ្ឍធនធានមនុស្ស ដោយយល់ឃើញថាធនធានមនុស្សគឺជាកម្លាំងចលករចាំបាច់បំផុតក្នុងការគ្រប់គ្រងទុនបម្រុងអន្តរជាតិប្រកបដោយជោគជ័យ។ ក្នុងដំណើរការគ្រប់គ្រងទុនបម្រុងអន្តរជាតិ ធនាគារជាតិនៃកម្ពុជាបានឆ្លងកាត់នូវបទពិសោធន៍ពីវិបត្តិហិរញ្ញវត្ថុធំៗជាច្រើន និងជាពិសេសវិបត្តិសុខភាពដែលបណ្តាលមកពីការរីករាលដាលនៃជំងឺកូវីដ-១៩ ដែលបានអូសបន្លាយចាប់តាំងពីចុងឆ្នាំ២០១៩ មក។ វិបត្តិនេះបានដាក់សម្ពាធ


ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ៤៨ ផ្លូវលេខ ១០២ កែងនឹងផ្លូវលេខ ១៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ , ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥១៣, ទូរស័ព្ទ / ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

ខ្លាំងដល់ស្ថិរភាពសេដ្ឋកិច្ច និងទីផ្សារហិរញ្ញវត្ថុពិភពលោក ដោយបានទាញទម្លាក់អត្រាការប្រាក់កាន់តែទាប ស្ទើរស្មើសូន្យ និងរហូតដល់កម្រិតអវិជ្ជមានសម្រាប់ទីផ្សារហិរញ្ញវត្ថុតំបន់អឺរ៉ូ។ អត្រាការប្រាក់អវិជ្ជមាន និងកម្រិតហានិភ័យតណទានកើនឡើង គឺជាបរិបទថ្មីមួយដែលមិនធ្លាប់មានពីមុន និងជាឧបសគ្គចម្បងសម្រាប់ការវិនិយោគទុនបម្រុងអន្តរជាតិរបស់ធនាគារជាតិនៃកម្ពុជា ប៉ុន្តែធនាគារជាតិនៃកម្ពុជានៅតែមានសមត្ថភាពគ្រប់គ្រាន់ក្នុងការគ្រប់គ្រងការវិនិយោគទុនបម្រុងប្រកបដោយ សុវត្ថិភាព សន្ទនីយភាព និងចំណូលសមរម្យ។ ជាក់ស្តែង គិតត្រឹមឆមាសទី១ ឆ្នាំ២០២១ នេះ បរិមាណទុនបម្រុងរបស់ធនាគារជាតិនៃកម្ពុជាមានចំនួនគ្រប់គ្រាន់ដែលអាចធានាលើការនាំចូលទំនិញនិងសេវាសម្រាប់គ្រាបន្ទាប់បានប្រមាណ ១០ខែ ខ្ពស់ជាងកម្រិតកំណត់អប្បបរមាចំនួន ៣ខែ សម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍។ កម្រិតខ្ពស់នៃទុនបម្រុងអន្តរជាតិបានអនុញ្ញាតឱ្យធនាគារជាតិនៃកម្ពុជាមានលទ្ធភាពគ្រប់គ្រាន់ក្នុងការគ្រប់គ្រងអត្រាប្តូរប្រាក់ ផ្គត់ផ្គង់តម្រូវការសន្ទនីយភាពក្នុងស្រុក ដើម្បីរក្សាស្ថិរភាពវិស័យហិរញ្ញវត្ថុ គរពូនទ្រព្យសម្បត្តិជាតិ និងបង្កើនជំនឿទុកចិត្តរបស់វិនិយោគិន។

## ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ជាទីមេត្រី!

ជាថ្មីម្តងទៀត ភាពជោគជ័យក្នុងការគ្រប់គ្រងទុនបម្រុងអន្តរជាតិរបស់ធនាគារជាតិនៃកម្ពុជា គឺបានមកពីការរួមចំណែកជាចម្បងពីកត្តាធនធានមនុស្សប្រកបដោយគុណវុឌ្ឍិ បទពិសោធន៍ និងក្រមសីលធម៌វិជ្ជាជីវៈខ្ពស់។ ការបណ្តុះបណ្តាលមន្ត្រីគ្រប់គ្រងទុនបម្រុងត្រូវបានអនុវត្តជាប្រចាំ តាមគ្រប់រូបភាព និងប្រកបដោយនិរន្តរភាព ដែលរួមមានការបណ្តុះបណ្តាលផ្ទៃក្នុង ការបណ្តុះបណ្តាលក្រៅប្រទេស សម្រាប់រយៈពេលខ្លី មធ្យម និងរយៈពេលវែង តាមរយៈការសហការជាមួយបណ្តាលធនាគារកណ្តាល ស្ថាប័នធនាគារឯកជន និងគ្រឹះស្ថានហិរញ្ញវត្ថុធំៗនៅលើពិភពលោក។ ជាងនេះទៀត កម្រិតជំនាញផ្នែកហិរញ្ញវត្ថុស្តង់ដារអន្តរជាតិត្រូវបានទទួលការលើកទឹកចិត្ត ដូចជា Chartered Financial Analyst (CFA) និង Certified Public Accountant (CPA) ជាដើម។ គិតមកដល់ពេលបច្ចុប្បន្ន មន្ត្រីគ្រប់គ្រងទុនបម្រុងរបស់ធនាគារជាតិនៃកម្ពុជាទទួលបានងារ CFA ចំនួន ២រូប ក្នុងនោះមួយរូបមានងារ CFA និងCPA និងមានមន្ត្រីជាច្រើនរូបទៀតដែលកំពុងសិក្សា CFA នៅគ្រប់កម្រិត។ ការរីកចម្រើននៃធនធានមនុស្សគួជាទីមោទននេះ បានជួយឱ្យធនាគារជាតិនៃកម្ពុជាមានលទ្ធភាពកសាងរចនាសម្ព័ន្ធគ្រប់គ្រងការវិនិយោគកាន់តែរឹងមាំ និងរីកចម្រើនតាមទាន់ការវិវត្តនៃទីផ្សារហិរញ្ញវត្ថុពិភពលោក។ ជាងនេះទៀត សមត្ថភាពជំនាញរបស់មន្ត្រីផ្នែកវិនិយោគទុនបម្រុងរបស់ធនាគារជាតិនៃកម្ពុជា ត្រូវបានទទួលស្គាល់ជាលក្ខណៈអន្តរជាតិ និងត្រូវបានទទួលការស្នើសុំចែករំលែកចំណេះដឹង និងបទពិសោធន៍ការគ្រប់គ្រងទុនបម្រុងអន្តរជាតិពីធនាគារកណ្តាលមួយចំនួនដូចជា ធនាគារកណ្តាលឡាវ ធនាគារកណ្តាលភូមា ធនាគារកណ្តាលអាហ្វានីស្ថាន ព្រមទាំងត្រូវបានទទួលការអញ្ជើញចូលរួមធ្វើជាវាគ្មិននៅក្នុងសិក្ខាសាលា និងកម្មវិធីបណ្តុះបណ្តាលជាលក្ខណៈអន្តរជាតិដែលរៀបចំឡើងដោយធនាគារពិភពលោក និងដៃគូវិនិយោគជាស្ថាប័នហិរញ្ញវត្ថុធំៗជាច្រើនទៀតផងដែរ។

ដោយមើលឃើញថា បេឡាជាតិសន្តិសុខសង្គមមានទស្សនវិស័យក្នុងការគ្រប់គ្រងមូលនិធិសន្តិសុខសង្គមដូចដែលធនាគារជាតិនៃកម្ពុជាកំពុងអនុវត្ត នាងខ្ញុំជឿជាក់ថា ការអនុវត្តអនុស្សរណៈយោគយល់នេះ នឹងផ្តល់ឱកាសដល់ ប.ស.ស ទទួលបាននូវការបណ្តុះបណ្តាលមួយដែលមានគុណភាពខ្ពស់ និងសមស្របតាមតម្រូវការជាក់ស្តែង ដើម្បីឈានទៅសម្រេចបានគោលដៅគ្រប់គ្រងការវិនិយោគមូលនិធិសន្តិសុខសង្គមប្រកបដោយសុវត្ថិភាព និងប្រសិទ្ធភាព។ នេះក៏ជាឱកាសមួយសម្រាប់មន្ត្រីគ្រប់គ្រងទុនបម្រុងរបស់ធនាគារជាតិនៃកម្ពុជាក្នុងការទទួលបាននូវបទពិសោធន៍ថ្មីបន្ថែមទៀតលើការចែករំលែកចំណេះដឹង និងបទពិសោធន៍ ព្រមទាំងអាចរួមចំណែកក្នុងការជួយ

គ្រប់គ្រងមូលនិធិសន្តិសុខសង្គមឱ្យមានការរីកចម្រើន ប្រកបដោយសុវត្ថិភាពខ្ពស់ ដើម្បីសម្រេចបាននូវគោលដៅរួម គឺការទ្រទ្រង់សុខមាលភាពរបស់ប្រជាជនកម្ពុជាប្រកបដោយឧត្តមភាព និងចីរភាព។

ជាចុងក្រោយ នាងខ្ញុំសូមថ្លែងអំណរគុណចំពោះវត្តមានឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ដែលបានចូលរួមក្នុងពិធីចុះអនុស្សរណៈយោគយល់នេះ និងសូមជូនពរ ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ព្រមទាំងក្រុមគ្រួសារ សូមមានសុខភាពល្អ កម្លាំងមាំមួន និងជោគជ័យគ្រប់ភារកិច្ច។

**សូមអរគុណ**!